ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២៣៣.អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការទទួលស្គាល់សហព័ន្ធជំឡូងមីកម្ពុជា (ស.ជ.ក.)

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

# សម្រេច

**មាត្រា១** :-

ទទួលស្គាល់ **សហព័ន្ធដំឡូងមីកម្ពុជា** (សរសេរជាអក្សរកាត់ ស.ដ.ក.) ជាស្ថាប័នឯកជនតែមួយគត់សម្រាប់វិស័យដំឡូងមីនៅកម្ពុជា ដែលស្ថិតក្រោមអភិបាលកិច្ចផ្នែកបច្ចេកទេសរបស់ក្រសួងពាណិជ្ជកម្ម។

**មាត្រា២** :-

**ស.ដ.ក.** ត្រូវដឹកនាំដោយប្រធានក្រុមប្រឹក្សាភិបាលនិងប្រធានសហព័ន្ធដែលកើតចេញពីការបោះឆ្នោត ស្របតាមលក្ខន្តិកៈនិងមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

**ស.ដ.ក.** ជាដៃគូជាមួយរាជរដ្ឋាភិបាលក្នុងការអនុវត្តគោលនយោបាយជាតិស្តីពីដំឡូងមីដោយធ្វើសកម្មភាពដូចខាងក្រោម៖

- ផ្សព្វផ្សាយ និងជំរុញការនាំចេញដំឡូងមី
- ចូលរួមកែលម្អផលិតកម្មដំឡូងមី និងជំរុញការងារកែច្នៃដំឡូងមី
- ចូលរួមក្នុងការងារសិក្សាស្រាវជ្រាវពូជដំឡូងមី
- ចូលរួមជាមួយក្រសួងពាណិជ្ជកម្ម ក្នុងការចរចាបើកច្រកទីផ្សារដំឡូងមីជាមួយបណ្តាប្រទេសជាដៃគូ
- ចូលរួមរៀបចំសន្និសីទ និងពិព័រណ៍ដំឡូងមីថ្នាក់ជាតិ និងអន្តរជាតិ
- ចូលរួមសកម្មភាពនានាដែលពាក់ព័ន្ធនឹងវិស័យដំឡូងមីក្នុងក្របខ័ណ្ឌតំបន់ និងអន្តរជាតិ
- សហការជាមួយក្រសួងពាណិជ្ជកម្មដើម្បីកំណត់ប្រភេទកសិផលអាទិភាពផ្សេងទៀតសម្រាប់ការនាំចេញ។

**មាត្រា៣** :-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។



ទ

**មាត្រា៤** :-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ១៣ កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ឧបសម្ព័ន្ធទី១**
**សញ្ញាសម្គាល់ និងគំរូត្រា**
**សមាគមសហព័ន្ធដំឡូងមីកម្ពុជា**

**ក. អំពីសញ្ញាសម្គាល់**

**ខ. អំពីគំរូត្រា**

ថ្ងៃសុក្រ ៦រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ពុទ្ធសករាជ ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៤

**ជ.ក្រុមប្រឹក្សាភិបាល**

**ប្រធាន**

**ច្រាយ សុន**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ឧបសម្ព័ន្ធទី២**
**រចនាសម្ព័ន្ធ**
**សមាគមសហព័ន្ធជំឡូងមីកម្ពុជា**




ថ្ងៃសុក្រ ៦រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ពុទ្ធសករាជ ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៤

**ជ.ក្រុមប្រឹក្សាភិបាល**

**ប្រធាន**

**ច្រាយ សុន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## ឧបសម្ព័ន្ធទី៣
## សមាសភាពដឹកនាំ
## សមាគមសហព័ន្ធជំឡូងមីកម្ពុជា

| ល.រ | គោត្តនាម និងនាម | ឈ្មោះស្ថាប័ន | តួនាទី/មុខតំណែង |
|---|---|---|---|
| ១ | ឧកញ៉ា **ច្រាយ សុន** | ក្រុមហ៊ុន ឃែភីថល ហ្វីង អ៊ិនវេសមេន អ៊ីមផត អិចផត | ប្រធាន |
| ២ | លោក **និន ចរិយា** | ក្រុមហ៊ុន រហោត់អាហ្គ្រោថេក ឯ.ក | អនុប្រធានទី១ ទទួលបន្ទុកផ្នែកលើកកម្ពស់ផលិតកម្ម |
| ៣ | លោក **សាន សេង** | | អនុប្រធានទី២ ទទួលបន្ទុកផ្នែកគ្រប់គ្រងខ្សែចង្វាក់ផ្គត់ផ្គង់ |
| ៤ | លោកស្រី **ហេង ចាន់ថាន់ធី** | សហគ្រាស វ៉ាយ អេច កាវ៉ាស | អនុប្រធានទី៣ ទទួលបន្ទុកផ្នែកលើកកម្ពស់ទីផ្សារក្នុងស្រុក និងជាហេរញ្ញិក |
| ៥ | លោក **ម៉ៅ កេន្ធរិទ្ធ** | ក្រុមហ៊ុន សាញ ហនុមាន ត្រេឌីង អ៊ីមផត អិចផត ឯ.ក | អនុប្រធានទី៤ ទទួលបន្ទុកផ្នែកជម្រុញការនាំចេញ |
| ៦ | ឯកឧត្តម **នី កន** | ក្រុមហ៊ុន នីកន អភិវឌ្ឍន៍ ត្រេឌីង អ៊ីមផត អិចផត | សមាជិក |
| ៧ | លោក **ឈៀង សុខវណ្ណនី** | សមាគមកសិករជំឡូងមីខ្មែរ | សមាជិក |
| ៨ | លោក **ស៊ឹង សុខខេន** | | សមាជិក |
| ៩ | លោក **សុខ សែន** | | សមាជិក |
| ១០ | លោក **គុណា ចន្ធី** | | សមាជិក |
| ១១ | លោក **ឡាយ ធីម** | | សមាជិក |
| ១២ | លោក **គ្រួច ច័ន្ទថុនា** | ក្រុមហ៊ុន ជួន គ្រួច ត្រេឌីង ឯ.ក | សមាជិក |

| | | | |
|---|---|---|---|
| ១៣ | លោក **ទ្រី គឹមស្រៀង** | | សមាជិក |
| ១៤ | លោក **គឿន សុខគេង** | | សមាជិក |
| ១៥ | លោក **សុផ្លា សុផ្លាន** | ក្រុមហ៊ុន វី7អេសឌី ឡូជីស្ទីក អេនខនសាល់ធេន ឯ.ក | អគ្គលេខាធិការ |

ថ្ងៃសុក្រ ៦រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ពុទ្ធសករាជ ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៤

**ជ.ក្រុមប្រឹក្សាភិបាល**

**ប្រធាន**

**ច្រាយ សុន**